# លក្ខន្តិកៈ
# សមាគមខ្មែររដ្ឋអូស្ត្រាលីខាងត្បូង

## មាត្រាទី១ - ឈ្មោះ

ឈ្មោះរបស់សមាគមគឺ សមាគមខ្មែរសាជីវកម្មរដ្ឋអូស្ត្រាលីខាងត្បូង ដែលចាប់ពីពេលនេះតទៅ ហៅថា "សមាគម "

## មាត្រាទី២ - គោលបំណង

គោលបំណងរបស់សមាគម គឺមានដូចតទៅនេះ៖

2.1 ផ្តល់សេវាកម្មដល់សមាជិកសហគមខ្មែរ ផ្នែក សុខមាលភាព គាំទ្រដល់ការសំរបខ្លួនចូលក្នុងសង្គម ការអប់រំភាសា និងសេវាកម្មផ្សេងទៀត ទាក់ទងនឹងសហគម ហើយដើម្បីនឹងជួយអោយសមាជិកសហគមទទួលយកការបំរើផ្សេងទៀតដែលមាននៅក្នុងសង្គមអូស្ត្រាលី ដោយអាស្រ័យលើថវិកាឧបត្ថម្ភដែលបានទទួល។

2.2 ថែរក្សាព្រមទាំងផ្សព្វផ្សាយ នូវទំនៀមទំលាប់ ប្រពៃណីយ៍ កេរ្តិ៍ដំណែល សាសនានិងភាសាខ្មែរ ហើយនិងបង្កើតសុច្ឆន្ទៈព្រមទាំងមិត្រភាពរវាងសង្គមអូស្ត្រាលីទាំងមូល។

2.3 ដើរតួនាទីជំនួសអោយសហគមខ្មែរនៅក្នុងរដ្ឋអូស្ត្រាលីខាងត្បូង លើបញ្ហារផ្សេងៗដែលមានចំណាប់អារម្មណ៍ដូចគ្នា។

2.4 ផ្តល់អោយនូវដំបូន្មាននិងធ្វើកិច្ចការជាដៃគូជាមួយនឹងក្រសួងរដ្ឋាភិបាលតាមលំដាប់ថ្នាក់ ដើម្បីធ្វើអោយប្រាកដថា យើងអាចផ្តល់សេវាកម្ម ទាក់ទងនឹងវប្បធម៌ និងធ្វើជាគំរូដែលចេះទទួលខុសត្រូវ ជូនដល់ប្រជាជនខ្មែរទាំងអស់ដែលរស់នៅក្នុងរដ្ឋអូស្ត្រាលីខាងត្បូង ។

2.5 សំរបសំរួលព្រមទាំងធ្វើសហការណ៍ជាមួយនឹងសហគមខ្មែរ និងរវាងសហគមខ្មែរ, អង្គការរដ្ឋនិងអង្គការក្រៅរដ្ឋព្រមទាំងសហគមនៃជាតិសាសន៍ដ៏ទៃទៀត ទាក់ទងនឹងចំណាប់អារម្មណ៍រវាងគ្នាទៅវិញទៅមក។

2.6 ជួយលើកដំកើងនិងលើកទឹកចិត្ត ដល់គ្រប់អ្នកដំណាងនិងអ្នកចូលរួមយ៉ាងសកម្មនៃសមាជិក សហគមខ្មែរទាំងអស់នៅក្នុងសមាគម, អោយចេះការធ្វើសហការរវាងគ្នាដើម្បីនឹងរកដំណោះ ស្រាយ លើបញ្ហារផ្សេងៗ។

2.7 ជាការចាំបាច់ដែលយើងត្រូវ រក្សាការផ្តល់ដំណឹងអំពីបញ្ហារផ្សេងៗទាក់ទងនឹងប្រជាជនខ្មែរ ដល់ទៅអង្គការរដ្ឋនិងអង្គការក្រៅរដ្ឋដែលមានជាប់ទាក់ទង។

2.8 ស្វែងរកនូវសេវាកម្មដែលចន្លោះ រឺក៏សេចក្តីត្រូវការនៅក្នុងសហគមខ្មែរដែលគ្មានសេវាកម្មផ្តល់ជូន ហើយនឹងជួយលើកដំកើងដល់សេវាកម្មនានាដែលសមរម្យ។

2.9 ធ្វើគ្រប់កិច្ចការផ្សេងទៀតដែលប្រហែលជាស្របទៅតាមគោលបំណងខាងលើ ហើយដើម្បីធ្វើអោយប្រាកដថា កិច្ចការទាំងនោះត្រូវទទួលធ្វើដោយសមស្របតាមសង្គមនិងក្នុងលក្ខណៈទទួលខុសត្រូវ។

## មាត្រាទី ៣ - សមាជិកភាព

3.1 សមាជិកគឺគួតែជាអ្នកដែលៈ

   a) ឧបត្ថម្ភនូវគោលបំណងខាងលើ
   b) បានបំពេញហ្វមចូលជាសមាជិក
   c) បង់ថ្លៃសមាជិក និង
   d) ទទួលអោយចូលជាសមាជិកដោយការយល់ព្រមពីមតិភាគច្រើននៃគណៈកម្មាធិការ

3.2 លេខាធិការរបស់សមាគមត្រូវតែ, ទទួលធ្វើជាបន្ទាន់ តាមតែអាច បន្ទាប់ពីគណៈកម្មាធិការកណ្តាលបានយល់ព្រមទទួល រឺ ក៏បដិសេធការដាក់ពាក្យសុំចូលជាសមាជិក, ដោយធ្វើជូនអ្នកដាក់ពាក្យសុំចូល សមាជិក

ជាលាយល័ក្ខណ៍អក្សរអំពីការសំរេចចិត្ត រឺបើសិនជាការដាក់ពាក្យសុំចូលជាសមាជិកបានត្រូវទទួលយល់ព្រម ត្រូវផ្ញើប័ណ្ណសមាជិកជូនទៅអោយសមាជិក។

3.3 ការដាក់ពាក្យសុំចូលជាសមាជិកនឹងត្រូវបិទចំនួនមួយខែ មុនពេលប្រជុំទូទៅប្រចាំឆ្នាំ ដែលត្រូវធ្វើសំរាប់ការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការកណ្តាល។

## មាត្រាទី៤ - ការចុះឈ្មោះចូលជាសមាជិក

4.1 លេខាធិការត្រូវតែរក្សាការចុះឈ្មោះរបស់សមាជិករបស់សមាគម ដោយមានៈ

a. ឈ្មោះពេញរបស់សមាជិក
b. អស័យដ្ឋានសំរាប់ទាក់ទងរឺទីលំនៅនិងអ៊ីម៉ែលរបស់សមាជិក
c. ថ្ងៃចុះឈ្មោះចូលជាសមាជិក
d. បើសិនជាអាច, ថ្ងៃដែលសមាជិកសុំលាលែង និង,
e. មូលហេតុសុំលាលែងពីសមាជិក

4.2 បញ្ជីរចុះឈ្មោះនេះ មានរក្សាទុកសំរាប់អោយសមាជិកពិនិត្យមើលដោយមិនគិតថ្លៃ បើសិនជាមានសំណើ

4.3 សមាជិករបស់សមាគម មិនត្រូវយកពត៌មានដែលទទួលបានពីបញ្ជីរចុះឈ្មោះសមាជិកសមាគមដើម្បីទាក់ទង, រឺផ្ញើសម្ភារៈទៅកាន់សមាជិករបស់សមាគមម្នាក់ទៀតក្នុងគោលបំណងផ្សាយដំណឹងសំរាប់ជាផលប្រយោជន៍នយោបាយ, សាសនា , អង្គការជួយសង្គ្រោះរឺ ផ្សាយពាណិជកម្ម, រឺក៏ ផ្តល់ដំណឹងនេះទៅអោយអ្នកណាម្នាក់ទៀត, ដោយដឹងថា គេនឹងយកពត៌មាននេះទៅប្រើក្នុងគោលបំណងខាងលើ

4.4 បទបញ្ញា លេខ 4.3 អាចលើកលែងបាន បើសិនជាសមាគមអនុញ្ញាត្តិអោយប្រើរឺក៏លាតត្រដាងពត៌មាននេះ

## មាត្រា ៥ - ការសុំលាលែងជាសមាជិក

5.1 សមាជិកម្នាក់ អាចសុំលាលែងជាសមាជិកសមាគមបាន ដោយការផ្តល់ដំណឹងជាលាយល័ក្ខអក្សរ នៃការសុំលាលែងអោយទៅលេខាធិកា,

5.2 ការសុំលាលែងនឹងមានប្រសិទ្ធភាពនៅពេលដែលលេខាធិកា បានទទួលសំបុត្រសុំលាលែង

5.3 គណៈកម្មាធិការកណ្តាល, ដោយធ្វើការបោះឆ្នោតយកមតិភាគច្រើន ពីរភាគបី, ប្រហែលជាអាចសំរេចចិត្តពីសមាជិកភាពរបស់សមាជិកណាម្នាក់ បើសិនជា សមាជិកនោះៈ

a. ប្រព្រឹត្ត រឺអាចនឹងប្រព្រឹត្តបទឧក្រិត, រឺ
b. មិនអនុវត្តតាមបទបញ្ញាដែលបានចែងខាងលើនេះ
c. មិនបង់ថ្លៃសមាជិកភាពបន្តចំនួនយ៉ាងហោចណាស់បីខែ
d. ប្រព្រឹត្តអំពើដែលយើងគិតថា វាអាចនឹងធ្វើអោយខូចផលប្រយោជន៍ រឺ ដែលលំអៀងដល់ចំណាប់អារម្មណ៍របស់សមាគម។

5.4 មុនគណៈកម្មការប្រតិបត្តិបញ្ឈប់សមាជិកអោយអស់សុពលភាព គណៈកម្មការត្រូវផ្តល់ហេតុផលអោយបានពេញលេញពីមូលហេតុនៃការបញ្ឈប់នោះ។

5.5 ប្រសិនបើបន្ទាប់ពីការគិតគូសំរេចពីគណៈកម្មការ ដែលបានផ្តល់ហេតុផល ហើយ នោះ លេខាធិការត្រូវសរសេរសំបុត្រជាផ្លូវការ ដើម្បីជូនដំណឹងដល់ សមាជិកដែលត្រូវបានដកពីសមាជិកភាពសមាគម។

## មាត្រា ៦ - បណ្តឹងឧទ្ធរណ៍ចំពោះការដកពីសមាជិកភាពឬការបដិសេធក្លាយជាសមាជិកសមាគម

6.1 ជនណាដែលបានដាក់ពាក្យសុំជាសមាជិកសមាគមហើយត្រូវបានបដិសេធឬជាសមាជិកហើយ តែត្រូវបាន

បញ្ឈប់វិញនោះ អាចសរសេរសំបុត្រជាផ្លូវការមកលេខាធិការ ដើម្បីប្តឹងតវ៉ារកហេតុផល។

6.2 សំបុត្រឧទ្ធរណ៍តវ៉ាជាផ្លូវការត្រូវសរសេរមកលេខាធិការក្នុងកំឡុងពេលមួយខែក្រោយពីការបញ្ឈប់ឬបដិសេធពីសមាជិកភាព។

6.3 នៅពេលលេខាធិការបានទទួលសំបុត្របណ្តឹងឧទ្ធរណ៍នោះ លេខាធិការ ត្រូវកោះហៅប្រជុំជាទូទៅក្នុងរយៈពេលមួយខែដើម្បីដោះស្រាយសេចក្តីតវ៉ាជា ផ្លូវការនោះ។

6.4 ការប្រជុំជាទូទៅដើម្បីសំរេចពីបណ្តឹងឧទ្ធរណ៍នោះនិងត្រូវសំរេចអោយបានក្នុងរយៈពេលបីខែបន្ទាប់ពីបានទទួលសំបុត្រតវ៉ាជាផ្លូវការហើយ។

6.5 បន្ទាប់ពីការប្រជុំជាទូទៅចប់ជាស្ថាពរហើយ សមាជិកឬអ្នកសុំចូលជាសមាជិក ត្រូវមានឱកាសផ្តល់ពីហេតុផលដ៏ពេញលេញទៅគណៈកម្មការពីរឿងមិនត្រូវដកសមាជិកភាពឬមិនត្រូវបដិសេធនៃការសុំចូលជាសមាជិករបស់គាត់។

6.6 ដូចគ្នាផងដែរគណៈកម្មការប្រតិបត្តិនិងសមាជិកគណៈកម្មការត្រូវផ្តល់ហេតុផលដ៏យុត្តិធម៌បំផុតអំពីការបញ្ឈប់ជនណាពីសមាជិកភាពឬបដិសេធមិនទទួលយកគាត់ជាសមាជិក។

6.7 បណ្តឹងឧទ្ធរណ៍ត្រូវតែសំរេចជាភាគច្រើនក្នុងការបោះឆ្នោតនៃសមាជិកដែលមានសិទ្ធិបោះឆ្នោត។

6.8 ជនណាដែលបានបដិសេធមិនអោយចូលជាសមាជិកឬត្រូវបានបញ្ឈប់ពីសមាជិកភាព ហើយមិនបានដាក់សំណើដើម្បីប្តឹងឧទ្ធរណ៍ក្នុងរវាងមួយខែនោះ លេខាធិការនិងត្រូវផ្តល់ជូនថវិកាសមាជិកភាពវិញ។

## មាត្រា ៧ - ការគ្រប់គ្រង

7.1 ការគ្រប់គ្រងនៃគណៈកម្មការប្រតិបត្តិត្រូវមានសុពលភាពត្រឹមតែមួយ អាណត្តិ ដែលកាន់តំណែងពីរឆ្នាំប៉ុណ្ណោះ ដែលបានចែង ក្នុងមាត្រាទី១០ នៃ ធម្មនុញ្ញ ឬលក្ខន្តិកៈ។

7.2 សមាសភាពនៃគណៈកម្មការ រួមមាន ប្រធាន អនុប្រធាន លេខាធិការ ហិរញ្ញឹក និងសមាជិកសកម្ម៦នាក់។

7.3 គណៈកម្មការត្រូវជួបជុំគ្នាប្រជុំអោយបានច្រើនលើកច្រើនដងអំពីអ្វីៗដែលទាក់ទិនក្នុងរឿងប្រតិបត្តិការសមាគមយ៉ាងហោចណាស់អោយបាន៤ដងក្នុងមួយឆ្នាំ។

7.4 សមាសភាពនៃការគ្រប់គ្រងការិយាល័យសមាគមត្រូវតែមាន៤រូបនៃ គណៈកម្មការប្រតិបត្តិ ដោយមាន២រូបប្រចាំការនៅទីនោះជានិច្ច។

7.5 ប្រធានសមាគមមានអំណាចកោះហៅប្រជុំឬសមាជិកនៃគណៈកម្មការ ប្រតិបត្តិក៏អាចកោះហៅប្រជុំបានដែរ តែត្រូវអោយមាន២រូប ទើបអាចធ្វើទៅបាន។

7.6 ការកំណត់ពេលវេលានៃរាល់ការប្រជុំ ត្រូវផ្តល់ជូនឬណាត់សំរាប់លើក ក្រោយទៀតនៅពេលបន្ទាប់ពីការប្រជុំហើយម្តងៗ ឬសរសេរផ្តល់ជូនជាផ្លូវការនៃការបរិច្ឆេត។ ក្នុងករណីបន្ទាន់គឺសំរេចជាទូទៅពីគណៈកម្មការប្រតិបត្តិ។

7.7 អ្នកគ្រប់គ្រងសមាគមឬសមាជិកគណៈកម្មការត្រូវអស់អភ័យឯកសិទ្ធិនៅពេល

- 7.7.1 ត្រូវបានលាលែងពីតំណែងជាផ្លូវការ
- 7.7.2 ត្រូវបានដកសមាជិកភាពសមាគមជាបណ្តោះអាសន្ន
- 7.7.3 ខកខានមិនបានមកប្រជុំចំនួនបីលើកជួនៗដោយគ្មានហេតុផល ហើយគណៈកម្មការទូទៅមិនអាចទទួលយកបាននៃហេតុផលនោះ
- 7.7.4 តំណែងមួយណាក៏ដោយនៃគណៈកម្មការនឹងត្រូវប្រកាសទំនេរ ប្រសិនបើអ្នកដែលកាន់ដំណែងនោះមិនបានធ្វើអ្វីៗអោយស័ក្តិសមនៃតួនាទីរបស់គាត់ ហើយភាគច្រើននៃគណៈ

កម្មការត្រូវបោះឆ្នោតយល់ស្រប។ សេចក្តីប្រកាសជាទូទៅនៃ តំណែងទំនេរនោះ និងត្រូវផ្តល់ដំណឹងជូនគ្រប់សមាជិកសមាគម។ ហើយអ្នក ដែលត្រូវបានដកពីតំណែងនោះ ត្រូវមានឱកាសបកស្រាយពីហេតុផលរបស់គាត់ផងដែរ នាពេលប្រជុំជាទូទៅ។

7.8 គណៈកម្មការប្រតិបត្តិអាចនៅដំណើរការដដែលទោះបីមានតំណែងទំនេរណាមួយក៏ដោយ អោយតែសមាសភាពគណៈកម្មការមិនក្រោមចំនួនកំណត់នៃច្បាប់ឬកូតានៃការគ្រប់គ្រង។

7.9 គណៈកម្មការអាចជ្រើសតាំងអ្នកណាម្នាក់ដើម្បីកាន់តំណែងនោះជា បណ្តោះអាស័ន្នទម្រាំដល់កំណត់ប្រជុំជាទូទៅប្រចាំឆ្នាំ ហើយអ្នកនោះត្រូវមាន សិទ្ធិឈរឈ្មោះជាស្វ័យប្រវត្តិ។

7.10 គណៈកម្មការអាចជ្រើសតាំងឬបង្កើតអនុគណៈកម្មការដើម្បីតម្រូវការអ្វី មួយសំរាប់សមាគម។ អនុគណៈកម្មការអាចកើតចេញពីសមាជិកភាពនៃ សមាគមក៏បាន ឬអ្នកមិនមែនជាសមាជិកក៏បាន តែត្រូវមានអ្នកណាម្នាក់ដើរ តួនាទីជាអ្នករាយការណ៍មកគណៈកម្មការប្រតិបត្តិអំពីសកម្មភាពរបស់ខ្លួន។

7.11 គណៈកម្មការអាចចាត់តាំងឬសហការជាមួយជនណាម្នាក់ដែលមាន ជំនាញឬចំណេះដឹងពិសេស ដើម្បីជួយនូវរាល់ការពិភាក្សាសំរេចអ្វីនានា។ ក៏បន្តែ ជននេះមិនអាចបោះឆ្នោតបានទេ។

7.12 គណៈកម្មការអាចចាត់តាំងសមាជិកណាម្នាក់ជាអ្នកគ្រប់គ្រងការិយាល័យ សមាគម តែត្រូវមានអ្នកទីពីរនៃសមាជិកគណៈកម្មការ ដើម្បីបំរើសេវាកម្ម ជាធម្មតាបាន។

7.13 គណៈកម្មការអាចចាត់តាំង ភ្នាក់ងារសាធារណៈ សំរាប់សមាគ ហើយត្រូវ ប្រាប់ដំណឹងនៃការតែងតាំងទៅក្រសួង អ្នកប្រើប្រាស់ទំនិញ។ ដូចគ្នាផងដែរ ភ្នាក់ងារសាធារណៈ រូបនេះត្រូវផ្តល់ពត៌មានអ្វីៗពីក្រសួងនោះមកវិញទៅតាម ច្បាប់។ ភ្នាក់សាធារណៈ ត្រូវកាន់តំណែងជាប់លុះត្រាណាគណៈកម្មការតែងតាំងអ្នកថ្មីមកជំនួស។

7.14 គណៈកម្មការអាចបញ្ចេញទស្សនៈវិស័យឬចំណាប់អារម្មណ៍ទៅលើអង្គការ ឬក្រុមណាដែលខ្លួនតំណាងនោះ ប៉ុន្តែត្រូវមានការបោះឆ្នោតយល់ព្រម ដើម្បីជា ផលប្រយោជន៍នៃគោលការសមាគម។

7.15 សមាជិកគណៈកម្មាធិកាមិនត្រូវអនុម័តអំពីកាសរសំរេចចិត្តណាមួយឡើយ ក្នុងករណីដែលគេ សមាជិកគ្រួសារជិតរឺឆ្ងាយរឺជាសហការីជិតដិតដែលមានការទាក់ទងនឹងផ្នែកថវិកាហើយក៏មិនត្រូវប្រើមុខនាទីរបស់ខ្លួនដើម្បីទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន, គ្រួសារជិតរឺឆ្ងាយ រឺសហការីជិតដិត។

7.16 សំនួរដែលលើកឡើងក្នុងអង្គប្រជុំរបស់គណៈកម្មាការត្រូវសំរេចដោយមតិភាគច្រើន ហើយក្នុងករណីដែលមានមតិស្មើគ្នាប្រធានអង្គប្រជុំត្រូវអោយបោះឆ្នោតដោយមានការពិគ្រោះនិងពិភាក្សាគ្នា។

## មាត្រាទី ៨ - អំណាច

8.1 អំណាចរបស់សមាគម គឺជាអំណាចដែលបានជាក្រិតក្រមរបស់សមាគមសាជីវកម្មហើយដោយគ្មានកំរិតនៃអំណាច សមាគមមានលទ្ធភាពគ្រប់គ្រងទ្រព្យសម្បត្តិ បើកនិងប្រើប្រាស់គណនេយ្យ ធ្វើវិនិយោគក្នុងស្ថាប័ណ្ណនិងចូលរួមធ្វើកិច្ចសន្យាចាំបាច់ រឺដែលមានការរាប់បញ្ចូលទាំហកិច្ចសន្យាការងារជាដើម។

8.2 គណៈកម្មាការនិងមានសិទ្ធិគ្រប់គ្រាន់ដើម្បីអនុវត្តអំណាចនៃការចាត់ចែងនិងគ្រប់គ្រងផ្នែកថវិកានិងទ្រព្យសម្បត្តិរបស់សមាគម អោយតែសមាគមមានសេចក្តីយល់ព្រមពីអង្គប្រជុំសាមញ្ញ មុននឹងខ្ចីលុយ, យកទ្រព្យសម្បត្តិសមាគមទៅដាក់ធានាក្នុងការខ្ចីលុយ រឺបោះចោលទ្រព្យសម្បត្តិដែលមានតម្លៃពី $5000 ឡើងទៅ។

## មាត្រាទី ៩ - អង្គប្រជុំសាមញ្ញ

9.1 សន្និបាតប្រចាំឆ្នាំត្រូវតែធ្វើយ៉ាងហោចណាស់មួយឆ្នាំម្តង ហើយមិនអោយហួសពីប្រាំខែ បន្ទាប់ពីដំណាច់នៃថវិកាប្រចាំឆ្នាំ។

9.2 របៀបវារៈនៃសន្និបាតប្រចាំឆ្នាំ ត្រូវតែៈ

9.2.1 បញ្ជាក់ពីកំណត់ហេតុនៃសន្និបាតប្រចាំឆ្នាំកន្លងមក

9.2.2 ទទួលរបាយការណ៍របស់ប្រធាន អំពីថវិកាប្រចាំឆ្នាំមុន

9.2.3 ទទួលរបាយការណ៍របស់ហេរញ្ញិកនិងតុល្យបញ្ជីនៃថវិកាដែលបានត្រួតពិនិត្យដោយល្អិតល្អន់សំរាប់ថវិកាប្រចាំឆ្នាំមុន ទៅនឹងគំរោងថវិកាប្រចាំឆ្នាំនេះ។

9.2.4 បោះឆ្នោតជ្រើសរើសរើជ្រើសរើសសាជាថ្មីនូវប្រធាននិងអនុប្រធាន ហើយនិងគណៈកម្មាធិកាផ្សេងទៀតក្នុងរយៈពេលពីរឆ្នាំម្តង។

9.2.5 ធ្វើកិច្ចផ្សេងទៀតដែលមានតែងតាមរបៀបវារៈមុនពេលអង្គប្រជុំចាប់ផ្តើម។

9.3 អង្គប្រជុំពិសេសត្រូវតែកោះហៅដោយលេខាធិកាក្នុងកំឡុងពេល២៨ថ្ងៃនៃការណែនាំពី គណៈកម្មាធិកា រឺបើមានស្នើសុំជាផ្លូវការពីសមាជិកគណៈកម្មាធិការបីរូប រឺសមាជិកសាមញ្ញ៦នាក់ ដោយមានសំបុត្របញ្ជាក់ជាលាយល័ក្ខអក្សរយ៉ាងច្បាស់លាស់ពីគំរោងនៅពេលប្រជុំ

9.4 កំណត់ប្រកាសមិនតិចជាង១៤ថ្ងៃនៅអង្គប្រជុំទូទៅនិងត្រូវបិទប្រកាសនៅទីស្នាក់ការរបស់សមាគមព្រមទាំងផ្សព្វផ្សាយដំណឹងដល់សមាជិកទាំងអស់ដែលមិនបានចេញចូលទីស្នាក់ការជាអលជ្ជី។

9.5 សមាជិកដែលមានសិទ្ធម្នាក់ មានសិទ្ធិនឹងបោះឆ្នោតនៅពេលអង្គប្រជុំទូទៅប្រចាំឆ្នាំដែលគេមានវត្តមាន។

9.6 ចំនួនចាំបាច់នៃការបើកអង្គប្រជុំ នឹងធ្វើឡើងបាន ដោយមានសមាជិក១០រូប រឺចំនួនពីរភាគបីនៃសមាជិកទាំងឡាយក្នុងប្រការណាដែលតិចជាងគេ។

9.7 បើសិនជាអង្គប្រជុំណាដែលគ្មានចំនួនចាំបាច់ដើម្បីបើកអង្គប្រជុំ ក្នុងកំលុង៣០នាទីនៃកាលបរិច្ឆេទកំណត់អង្គប្រជុំនោះ ការប្រជុំនឹងត្រូវលើកទៅថ្ងៃ ក្រោយ ក្នុងកំឡុងមិនលើសពី២៨ថ្ងៃ។

## មាត្រាទី ១០ - ការបោះឆ្នោតជ្រើសរើសអ្នកទទួលបន្ទុកការិយាល័យ និងសមាជិកសាមញ្ញ

10.1 បេក្ខជនទាំងអស់ដែលឈរឈ្មោះ ក្នុងអង្គប្រជុំប្រចាំឆ្នាំត្រូវៈ

10.1.1 មានដើមកំណើតជាខ្មែរ លើកលែងតែអ្នកនោះអាចឈរឈ្មោះជាសមាជិកសាមញ្ញដោយស្របទៅនឹងប្រការ 10.1.2។

10.1.2 អ្នកដែលគ្មានដើមកំណើតជាខ្មែរ អាចឈរឈ្មោះជាសមាជិកសាមញ្ញបាន លុះត្រាតែអ្នក ដែលជាប់ឈ្មោះនោះមិនលើសពី២នាក់ ឬ២០ភាគរយនៃគណកម្មការរឺដែលតិចជាងនេះ។

10.1.3 ទំនាក់ទំនងទៅនឹង វគ្គ10.5 ត្រូវជាសមាជិកដែលមានសមាជិកភាពរបស់សមាគមយ៉ាងតិចក្នុងរយៈ១២ខែមុនការឈរឈ្មោះ។

10.1.4 ត្រូវចេះភាសារអង់គ្លេសល្អគ្រប់គ្រាន់ក្នុងការយល់ដឹងនូវឯកសារ ដែលជួបប្រទះ ដើម្បីបំពេញគោលបំណងរបស់សមាគម។

10.1.5 ប្តេជ្ញាបំរើសហគមន៍ទាំងមូល ដោយគ្មានលំអៀងទៅលើនយោបាយឬសាសនាណាមួយឬដោយគ្មាន គិតប្រយោជន៍ផ្ទាល់ខ្លួនឡើយ។

10.1.6 ជាអ្នករស់នៅអូស្ត្រាលីជាអចិន្ត្រៃយ៍។

10.1.7 ជាអ្នកមានលក្ខណៈចរិតល្អ។

10.1.8 មិនមែនជាអ្នកជំនួញរលំ ឬជាអ្នកដែលមិនអាចសងបំណុលគេបាន។

10.1.9 មិនមែនជាអ្នកជាប់ទោសអ្វីមួយ ដែលនៅមានការកាត់ទោសចូលពន្ធនាគារទោះជាព្យួរទោសឬអត់

10.2 បេក្ខជនអាចឈរឈ្មោះជាអ្នកចាត់ចែង ឬជាសមាជិកសាមញ្ញបានប៉ុន្តែអាចយកបានតែមួយតំណែងទេ។

10.3 ការជ្រើសរើសបេក្ខជនឲ្យឈរឈ្មោះសំរាប់បោះឆ្នោតជាប្រធាន រឺជាសមាជិកសាមញ្ញរបស់គណកម្មការ ត្រូវ

តែ៖

10.3.1 ធ្វើជាលាយលក្ខអក្សរ ដោយមានហត្ថលេខារបស់សមាជិកបង់លុយរបស់សមាគមយ៉ាង ហោច ណាស់មួយនាក់ និងរួមទាំងលិខិតយល់ព្រមរបស់បេក្ខជន។

10.3.2 ផ្ញើរទៅលេខាធិការសមាគមមិនតិចជាងប្រាំពីរ (៧)ថ្ងៃ មុនកាលបរិច្ឆេតសំរាប់ប្រជុំ វិសាមញ្ញប្រចាំឆ្នាំ។

10.4 សមាជិកបច្ចុប្បន្នអាចឈរឈ្មោះឡើងវិញដោយមិនចាំបាច់មានការតែងតាំង។

10.5 បើសិនជាបេក្ខជនឈរឈ្មោះមិនមានគ្រប់ចំនួនក្នុងគណៈកម្មាធិការ បេក្ខជនឈរឈ្មោះត្រូវចាត់ទុកជាជាប់ឆ្នោត ហើយការតែងតាំងបេក្ខជនបន្ថែមទៀតអាចធ្វើឡើងនៅក្នុងអង្គប្រជុំវិសាមញ្ញប្រចាំឆ្នាំ។បេក្ខជនតែងតាំងនេះត្រូវតែជាសមាជិកបង់លុយរបស់សមាគមយ៉ាងហោចបានបួន(៤)សប្តាហ៍។

10.6 បើសិនជាចំនួនបេក្ខជនស្មើនឹងចំនួនតំណែងទំនេរក្នុងគណៈកម្មាធិការ បេក្ខជននោះត្រូវចាត់ទុកជាជាប់ឆ្នោតជាធរមាន។

10.7 បើសិនជាចំនួនបេក្ខជនលើសចំនួនតំណែងគណៈកម្មាធិការ ការបោះឆ្នោតត្រូវតែធ្វើឡើង នៅក្នុងអង្គប្រជុំវិសាមញ្ញប្រចាំឆ្នាំ យោងតាមលក្ខខណ្ឌទី១១នៃលក្ខន្តិកៈ។

10.8 បើសិនជាមានបេក្ខជនឈរឈ្មោះក្នុងពេលបោះឆ្នោត គណៈកម្មាធិការបច្ចុប្បន្នមានកាតព្វកិច្ចបន្តការគ្រប់គ្រងសមាគម រហូតដល់ការបង្កើតគណៈកម្មាធិការថ្មី។

10.9 ការប្រជុំលើកដំបូងបន្ទាប់ពីការបោះឆ្នោត គណៈកម្មាធិការត្រូវជ្រើសរើសអនុប្រធាន ហិរញ្ញិក និងលេខាធិការ ក្នុងចំណោមសមាជិកគណៈកម្មាធិការ។

## មាត្រាទី ១១ - ការបោះឆ្នោត

11.1 ការបោះឆ្នោតរើសតំណែងប្រធាននិងសមាជិកគណៈកម្មាធិការ ត្រូវធ្វើឡើងដោយបោះឆ្នោតសំងាត់។

11.2 មិនទទួលការបោះឆ្នោតតាមវិធីផ្ញើសំបុត្រ លើកលែងតែសមាជិកដែលមានជំងឺហើយនៅសំរាកក្នុងមន្ទីរពេទ្យ។

## មាត្រាទី ១២ - ប្រធាន

12.1 ប្រធានត្រូវរក្សាត្រារបស់សមាគម ហើយអាចប្រើត្រានេះដោយការសំរេចយល់ព្រមរបស់គណៈកម្មាធិការ ឬពីអង្គប្រជុំវិសាមញ្ញដែលមានវត្តមានសមាជិកគណៈ កម្មាធិការពីរ(២)រូប រួមទាំងមានអ្នកកាន់បញ្ជីមួយនាក់យ៉ាងតិច។

12.2 ប្រធានត្រូវធ្វើប្រធានអង្គប្រជុំ ក្នុងការប្រជុំគណៈកម្មាធិការប្រតិបត្តិ គណៈកម្មាធិការឬប្រជុំវិសាមញ្ញ លើកលែងតែអវត្តមានរបស់ប្រធាន ឬតាមការស្នើរបស់ប្រធានឬតាមមតិភាគច្រើនរបស់អង្គប្រជុំ អនុប្រធានឬសមាជិកណាម្នាក់អាចត្រូវចាត់តាំងជាប្រធាននៃអង្គប្រជុំនោះ។

12.3 នៅក្នុងអង្គប្រជុំនិមួយៗ ប្រធានអង្គប្រជុំត្រូវមានការគិតគូរទុកផ្ទាល់ខ្លួនពីការបោះឆ្នោត ហើយត្រូវបោះឆ្នោតក្នុងពេលដែលមានសន្លឹកឆ្នោតស្មើគ្នា។

12.4 ប្រធានសមាគមត្រូវរៀបចំរបៀបវារៈសំរាប់ការប្រជុំគណៈកម្មាធិការនិងប្រជុំវិសាមញ្ញដោយពីគ្រោះយោបល់ជាមួយសមាជិកគណៈកម្មាធិការ។

12.5 ប្រធានអង្គប្រជុំត្រូវលើកទឹកចិត្តសមាជិកទាំងអស់ឲ្យចូលរួមប្រជុំហើយត្រូវចាត់ចែងការតាមលំដាប់លំដោយ។

12.6 ប្រធានត្រូវធ្វើជាអ្នកនាំពាក្យ លើកលែងតែគណៈកម្មាធិការ ឬអង្គប្រជុំវិសាមញ្ញបានតែងតាំងអ្នកនាំពាក្យណា

ម្នាក់។ អ្នកនាំពាក្យត្រូវនិយាយតាមលក្ខខណ្ឌដែលបានចែងរួចស្រេច ឬនៅពេលបន្ទាប់ពីការពិគ្រោះយោបល់ជាមួយសមាជិកគណៈកម្មាធិការយ៉ាងតិចពីរ (២)រូប។

12.7 សមាជិកណាម្នាក់អាចធ្វើជាប្រធានបានរយៈពីរ(២)អណត្តិជាប់គ្នា។

## មាត្រាទី ១៣ - ហេរញ្ញិក

13.1 ហេរញ្ញិកត្រូវតែដាក់បញ្ចូលថវិការដែលបានទទួលទាំងអស់ ទៅក្នុងគណនេយ្យរបស់សមាគមតាមការសំរេចរបស់គណៈកម្មាធិការ។ ការចំណាយត្រូវចាយជាក្រដាសប្រាក់ដោយសាច់ប្រាក់តិចតួច ឬ ចាយជាសែកដែលមានហត្ថលេខាពីរ(២)ដែលបានតែងតាំងក្នុងចំណោមហត្ថលេខីមិនលើសពីប្រាំ(៥)រូបពីសមាជិកគណៈកម្មាធិការ។

13.2 ការចំណាយធំៗឬមិនប្រក្រតីដែលមានចំនួនតិចជាងប្រាំពាន់(៥០០០) ត្រូវមានការអនុញ្ញាតិជាមុនពីគណៈកម្មាធិការ។

13.3 ការចំណាយធំៗឬមិនប្រក្រតីដែលមានចំនួនប្រាំពាន់(៥០០០) ឬច្រើនជាងនេះ ត្រូវតែបានសំរេចជាមុនសិនពីអង្គប្រជុំវិសាមញ្ញពីសេសដោយមានការអនុមត័ពីរភាគបី(២/៣)នៃវត្តមានសមាជិកគណកម្មាធិការ។

13.4 ហេរញ្ញិកត្រូវរក្សាទុកនូវកំណត់ត្រាចំណូលនិងចំណាយទាំងអស់ និងកិច្ចការចំណាយដទៃទៀត។ សមាជិកទាំងអស់មានសិទ្ធិសុំពិនិត្យកំណត់ត្រាហេរញ្ញវត្ថុទាំងអស់។

13.5 ហេរញ្ញិកត្រូវធានារៀបចំផែនការហេរញ្ញវត្ថុនិងរបាយការណ៍ ហើយត្រូវដាក់ របាយការណ៍ហេរញ្ញវត្ថុនេះទៅគណកម្មាធិការពិនិត្យ។

13.6 ហេរញ្ញិកត្រូវធ្វើរបាយការណ៍ហេរញ្ញវត្ថុប្រចាំឆ្នាំ ដោយរួមទាំងគណនីចំណូលនិងចំណាយ របាយការណ៍ទ្រព្យសម្បត្តិនិងបំណុល ឬធ្វើរបាយការណ៍គណនីនៃប្រាក់ចំណូលនិងការចំណាយនិងតារាងតុល្យការមួយនៅពេលដំណាច់ឆ្នាំ ដែលត្រូវចាប់ផ្តើមនៅថ្ងៃទី១ខែកក្កដាដល់ថ្ងៃទី៣០ខែមិនា លើកលែងតែមានការកែប្រែក្នុងអង្គប្រជុំវិសាមញ្ញ។

13.7 ហេរញ្ញិកត្រូវប្រាកដថា របាយការណ៍ថវិការប្រចាំឆ្នាំបានពិនិត្យជំរះបញ្ជីរួចហើយមុននឹងបង្ហាញទៅអង្គប្រជុំវិសាមញ្ញ។ អ្នកជំរះបញ្ជីឯករាជនោះត្រូវតែបានជ្រើសរើសឡើងជាមុន ដោយគណកម្មាធិការសមាគម ហើយល្ពឹកណាបើមានការផ្លាស់ប្តូរអ្នកជំរះបញ្ជីនោះ ហេរញ្ញិកត្រូវតែរាយការណ៍ពីការផ្លាស់ប្តូរនេះ នៅក្នុងរបាយការណ៍ថវិការដល់អង្គប្រជុំវិសាមញ្ញប្រចាំឆ្នាំ។

## មាត្រាទី ១៤ - លេខាធិការ

14.1 លេខាធិការត្រូវតែជូនដំណឹងអំពីការប្រជុំ យោងតាមបទបញ្ញត្តិរបស់លក្ខន្តិកៈ។

14.2 លេខាធិការត្រូវតែរក្សាកំណត់ត្រារបស់សមាគមរួមទាំង៖

- លក្ខន្តិកៈនិងច្បាប់គោលការណ៍
- បញ្ជីសមាជិក
- បញ្ជីកំណត់ហេតុប្រជុំនិងលិខិតជូនដំណឹង
- សំណុំលិខិតឆ្លើយឆ្លង
- កំណត់ត្រាដាក់ពាក្យសុំ និង
- របាយការណ៍ផ្សេងៗដែលសមាគមបានធ្វើឬធ្វើឡើងក្នុងនាមសមាគម។

14.3 នៅពេលដែលមានអវត្តមានរបស់លេខាធិការ ឬមានការស្នើសុំពីលេខាធិការឬក៏មានការស្នើភាគច្រើនពីអង្គប្រជុំនោះ សមាជិកម្នាក់ទៀតអាចតែងតាំងបាន ឲ្យធ្វើជាលេខាធិការកត់ត្រាកំណត់ហេតុអង្គប្រជុំ។

## មាត្រាទី ១៥. - បុគ្គលិក

15.1 បុគ្គលិកដែលបានទទួលប្រាក់ខែពីសមាគម និងអ្នកស្ម័គ្រចិត្តទាំងអស់ត្រូវគោរពតាមច្បាប់និងវិធានទម្រង់ការនៅកន្លែងធ្វើការនៃសមាគម។

15.2 បុគ្គលិកធ្វើការអោយសមាគម អាចជាសមាជិកសមាគម ឬជាសមាជិកអនុគណៈកម្មការ ណាមួយបាន។

15.3 បុគ្គលិកដែលបានទទួលប្រាក់ខែជាទៀងទាត់ពីសមាគមអាចជាសមាជិករបស់គណៈកម្មការបាន ប៉ុន្តែមិនត្រូវចូលរួមធ្វើការសំរេចចិត្តក្នុងកិច្ចការបង់ប្រាក់ឡើយ បើសិនជា មានការស្នើសុំភាគច្រើនពីគណៈកម្មការ។

## មាត្រាទី ១៦ - កំណែលក្ខន្តិកៈនិងច្បាប់

16.1 លក្ខន្តិកៈនេះអាចលុបឬកែបាន ដោយការសំរេចចេញពីសមាជិកដែលមានវត្តមានពីរភាគបី និងការបោះឆ្នោតនៅពេលប្រជុំសាមញ្ញមួយ។ ការប្រកាសប្រាប់ទៅសមាជិកក្នុងរយៈពេលយ៉ាងតិច១៤ថ្ងៃ ថានឹងមានសំណើលុបឬកែលក្ខន្តិកៈនេះនៅពេលប្រជុំសាមញ្ញ ហើយនិងកម្មវត្ថុនៃសំណើនេះត្រូវតែពន្យល់ប្រាប់នៅអង្គប្រជុំសាមញ្ញនៅពេលមុនបើកអង្គប្រជុំនេះតាមសំណូមពរពីសមាជិកណាមួយ។

16.2 ក្បួនសំរាប់ការចាត់ចែងដ៏សមរម្យរបស់អង្គប្រជុំនិងកិច្ចការប្រជុំ អាចរៀបធ្វើឡើងអាចលុបចោល ឬកែបានដោយការប្រជុំសាមញ្ញមួយ ឬដោយការប្រជុំរបស់គណៈ កម្មការដោយយោលទៅលើការមិនយល់ព្រមជាបន្តបន្ទាប់នៅអង្គប្រជុំសាមញ្ញមួយ ព្រមទាំងមានដំណឹងប្រាប់ជាលាយលក្ខណ៍អក្សរ (និងដំណឹងពីសំណើក្បួនថ្មីពីការលុបឬកំណែនេះ) ផ្ញើរជូនទៅសមាជិកទាំងអស់  យ៉ាងតិច១៤ថ្ងៃមុន។

## មាត្រាទី ១៧ - ការទទួលខុសត្រូវទ្រព្យសម្បត្តិនិងការរំសាយ

17.1 សមាជិកមានសិទ្ធិអំណាចនៅក្នុងគណៈកម្មការដែលបានរងបំណុលណាមួយ ឬរងការទទួលខុសត្រូវក្នុងបុព្វហេតុធ្វើកិច្ចការបំរើសមាគម នឹងត្រូវបានសមាគមទទួលខុសត្រូវសំណងជំនួស ដោយមិនអោយអ្នកនោះត្រូវខាតបង់ឡើយ។

17.2 ទ្រព្យចំណូល និងថវិការរបស់សមាគមត្រូវប្រើសំរាប់តែពង្រីកគោលការណ៍និងបំរើកិច្ចការសមាគមប៉ុណ្ណោះ មិនត្រូវចំណាយឬផ្ទេរបង្វែរទៅអោយសមាជិកឬញាតិសន្តានរបស់សមាជិកណាឡើយ តែមិនត្រូវហាមឃាត់ទេ ប្រសិនបើបង់ប្រាក់ដល់ជនណាដែលបានជួយដល់កិច្ចការបំរើឬជួយពង្រីកគោលការណ៍សមាគម និងដោយគ្មានយកការស្រឡាញ់ចូលចិត្តជាងជ្រុលហួសហេតុមកប្រើឡើយ។

17.3 ក្នុងការរំសាយ សម្បត្តិទ្រព្យដែលនៅសល់ពីការសងជំពាក់តាមច្បាប់ហើយត្រូវផ្ទេរទៅអោយអង្គការផ្សេងដែលមានគោលការណ៍ស្រដៀងគ្នានឹងសមាគម ឬអោយទៅអង្គការមនុស្សធម៌ ដោយមានការសំរេចពីសមាគម នៅលើមូលហេតុថា៖

17.3.1 អង្គការផ្សេងនោះមានការហាមឃាត់ក្នុងការចែកចាយថវិកានិងធនធានដល់ សមាជិកដូចបានបញ្ជាក់ខាងលើ។

17.3.2 បើសមាគមនោះបានទទួលព្រមព្រៀងអនុលោមតាមប្រការទី៣០នៃមាត្រារបស់ ក្រសួងពន្ធអាករ ហើយអង្គការនោះត្រូវបានទទួលការយល់ព្រមផង។

17.3.3 សមាគមមិនអាចរំសាយបានទេ លើកលែងតែមានការយល់ព្រមយ៉ាងតិចបីភាគបួននៃវត្តមានសមាជិក និងមានការបោះឆ្នោតនៅក្នុងកិច្ចប្រជុំមួយដែលបានកោះហៅមកក្នុងបំណងដើម្បីរំសាយ ដោយបានជូនដំណឹងជាលាយលក្ខណ៍អក្សរមុន យ៉ាងតិចមួយខែ រួមទាំងការផ្តល់ដំណឹងពីសំណើរំសាយនេះដល់សមាជិកទាំងអស់ផង៕